# ដំណឹងជ្រើសរើសកម្មសិក្សាការី

មន្ទីរសារការីភ្នំពេញ ត្រូវបានបង្កើតឡើងដោយអនុក្រឹត្យលេខ ១៣៨ អនក្រ.បក ចុះថ្ងៃទី០១ ខែតុលា ឆ្នាំ២០១៥ របស់ប្រមុខរាជរដ្ឋាភិបាល ដើម្បីបំពេញបេសកកម្មមួយចំនួនរបស់សារការីក្នុងការធានាភាពស្របច្បាប់ និងសុវត្ថិភាពតាមផ្លូវច្បាប់នូវរាល់លិខិតគតិយុត្ត និងកិច្ចសន្យានានារបស់អតិថិជន។

មន្ទីរសារការីភ្នំពេញ ត្រូវការជ្រើសរើសកម្មសិក្សាការីចំនួន ០២ រូប ដែលមានបំណងទទួលបានបទពិសោធន៍ការងារពាក់ព័ន្ធនឹងវិស័យច្បាប់នៅមន្ទីរសារការីភ្នំពេញ។

## អំពីភារកិច្ច

- ធ្វើការស្រាវជ្រាវផ្នែកច្បាប់
- តាក់តែងឯកសារ និងកិច្ចសន្យាផ្សេងៗ
- បកប្រែឯកសារផ្នែកច្បាប់ ឬឯកសារពាក់ព័ន្ធដទៃទៀតផ្សេងទៀត ដូចជា កិច្ចសន្យា និងលក្ខន្តិកៈក្រុមហ៊ុន ជាអាទិ៍
- បំពេញការងារផ្សេងទៀតដែលមន្ទីរសារការីផ្តល់ឱ្យ។

## អំពីកត្តាគុណវុឌ្ឍិ

- ត្រូវមានកំរិតវប្បធម៌បរិញ្ញាបត្រផ្នែកនីតិសាស្ត្រ ឬនិស្សិតដែលបានបញ្ចប់ការសិក្សាឆ្នាំទី ៣ ផ្នែកនីតិសាស្ត្រ
- ចេះប្រើប្រាស់កំព្យូទ័រ (Word & Excel) និងអ៊ិនធើណែត
- ចេះភាសាអង់គ្លេស (ចេះភាសាបារាំងកាន់តែប្រសើរ)

ចំពោះបេក្ខជនដែលមានចំណាប់អារម្មណ៍ សូមផ្ញើប្រវត្តិរូបសង្ខេប និងលិខិតបញ្ជាក់អំពីចំណាប់អារម្មណ៍របស់ខ្លួនមកមន្ទីរសារការីភ្នំពេញ ដែលមានអាសយដ្ឋានស្ថិតនៅអាគារកាណាឌីយ៉ាលេខ ៣១៥ (ជាន់ទី ១២) ផ្លូវព្រះអង្គដួង កែងមហាវិថីព្រះមុនីវង្ស សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ឬតាមរយៈអ៊ីម៉ែល info@ppnp.com.kh ឱ្យបានមុនថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១៧ វេលាម៉ោង ១២:០០ នាទី។

*បញ្ជាក់៖ កម្មសិក្សាការីនឹងទទួលបានប្រាក់ឧបត្ថម្ភពីមន្ទីរសារការីភ្នំពេញផងដែរ។*

*សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនងតាមរយៈទូរស័ព្ទលេខ ០២៣ ៤៣១ ៧៨៩។*

រាជធានីភ្នំពេញ ថ្ងៃព្រហស្បតិ៍ ទី១៣កើត ខែអាសាឍ ព.ស ២៥៦១
ត្រូវនឹងថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០១៧

ព្រះរាជាណាចក្រកម្ពុជា មន្ទីរសារការីភ្នំពេញ ម.ស.ភ.ព P.P.N.P PHNOM PENH NOTARY PUBLIC KINGDOM OF CAMBODIA

សារការី ស៊ុន តុលា

អាគារកាណាឌីយ៉ា លេខ៣១៥ (ជាន់ទី១២) ផ្លូវព្រះអង្គឌួង (ផ្លូវលេខ១១០) កែងមហាវិថីព្រះមុនីវង្ស (ផ្លូវលេខ៩៣) សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ
Website: www.ppnp.com.kh | E-mail: info@ppnp.com.kh | Tel: 023 431 789 | Fax: 023 431 678